# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

កាវិយាល័យផ្នែក កម្មវិធីសិក្សា ការបង្ហាត់បង្រៀន និង ការវាយតម្លៃ

440 NORTH BROAD STREET
PHILADELPHIA, PA 19130


**លក្ខណៈពិសេស និង ការជួយសម្រួល នៃការប្រឡង Keystone/PSSA សម្រាប់ ឆ្នាំ២០១៧-១៨**

- នៅពេលប្រឡង សិស្សានុសិស្សទាំងអស់មានការជ្រើសរើសខ្លះ ដូចជាការប្រើពេលវេលាយូរ និង អានឮៗ គ្រប់ផ្នែកទាំងអស់ នៃវិញ្ញាសា គណិតវិទ្យា វិទ្យាសាស្ត្រ ពិជគណិត១ និង ជីវវិទ្យា និងនៅផ្នែកខ្លះ នៃអក្សរសិល្ប៍អង់គ្លេស ។ល។
- ការជ្រើសរើសដែលមានសម្រាប់សិស្សទាំងអស់ ហៅថា «លក្ខណៈពិសេសនៃការប្រឡង»
- ការជ្រើសរើសដែលមានសម្រាប់ សិស្សពិការ សិស្ស EL និងសិស្សដែលមាន 504 Plan ដែលត្រូវការ ដើម្បីឲ្យពួកគេអាចចូលរួមក្នុងការវាយតម្លៃ ហៅថា « ការជួយ   សម្រួល»។ ហេតុដូច្នេះ ការជួយសម្រួល គឺជាការអនុវត្តន៍ដែលផ្តល់ឲ្យមានសមភាពសិស្សានុសិស្សទាំងអស់ ក្នុងការប្រឡងគ្រប់ផ្នែកនៃវិញ្ញាសា។
- ការជួយសម្រួល បានត្រូវចែកចេញជា ៤ ផ្នែក៖ ការបង្ហាញ ការឆ្លើយតប ការរៀបចំ និង ពេលវេលា (Presentation, Response, Setting, and Timing)។
- ការជួយសម្រួល ទាំងអស់ ដែលមានសម្រាប់ការប្រឡង ឃីស្តូន (Keystone) ក៏មានសម្រាប់ការប្រឡង PSSA ដែរ។
- **គឺជាការសំខាន់ ក្នុងការកត់សម្គាល់ថា ការជួយសម្រួលខ្លះ គឺសម្រាប់តែការពន្យល់ណែនាំ ប្រហែលជាមិនអាចប្រើសម្រាប់ការប្រឡងទូទៅបានទេ។**
- ការជួយសម្រួល ត្រូវតែស្របទៅតាមសេចក្តីត្រូវការរបស់សិស្ស សិស្សត្រូវតែសុខចិត្តទទួលការជួយសម្រួលទាំងនោះ ហើយសិស្សត្រូវតែចូលរួមក្នុងការជ្រើសរើសរបស់ពួកគេ (សូមមើល«ព័ត៌មានជំនួយបន្ថែម» នៅក្នុងសេចក្តីណែនាំអំពីការជួយសម្រួល សម្រាប់ការប្រឡង PSSA និង ឃីស្តូន ឆ្នាំ ២០១៨*)។
- ការអនុវត្តន៍ដែលល្អបំផុតក្នុងការជ្រើសរើស ការជួយសម្រួល សម្រាប់ការប្រឡង គឺត្រូវប្រើ ការជួយសម្រួល ដែលជាទម្លាប់ធ្លាប់ជួយដល់សិស្ស មុនពេលប្រឡង ហើយបានកត់ត្រាទុកពីការប្រើដែលមានប្រសិទ្ធភាព។ វាមិនមែនជាការអនុវត្តន៍ដ៏ល្អនោះទេ ចំពោះការផ្តល់ ការជួយសម្រួលក្នុងពេលប្រឡង ដែលតាមធម្មតាសិស្សមិនដែលធ្លាប់បានទទួល។

**ការជួយសម្រួល មានសម្រាប់តែសិស្សានុសិស្សដែលត្រូវការរៀនភាសាអង់គ្លេស (ELs)**

មាន ការជួយសម្រួលដោយស្ម័គ្រចិត្តបីដោយឡែក ដែលអនុញ្ញាតឲ្យសម្រាប់តែសិស្ស ELs៖

- ១) វចនានុក្រមដែលបកប្រែមួយពាក្យៗ ដែលគ្មាននិយមន័យ រូបភាព ឬតភ្ជាប់តាមអ៊ិនធ័រណិត... អនុញ្ញាតឲ្យប្រើក្នុងពេលប្រឡង ឃីស្តូន ផ្នែក ពិជគណិត១ និង ជីវវិទ្យា និង ការប្រឡង PSSAs ផ្នែក គណិតវិទ្យា និង វិទ្យាសាស្ត្រ តែប៉ុណ្ណោះ (មានសម្រាប់សិស្ស ELs **ទាំងអស់** ដោយមិនគិតពីចំនួនឆ្នាំដែលពួកគេបានរស់នៅក្នុងប្រទេសនេះ)
- ២) គេអនុញ្ញាតឲ្យមាន អ្នកបកប្រែភាសាដែលមានសមត្ថភាព**... ក្នុងពេលប្រឡង ឃីស្តូន ផ្នែក ពិជគណិត១ និង ជីវវិទ្យា និង ការប្រឡង PSSAs ផ្នែក គណិតវិទ្យា និង វិទ្យាសាស្ត្រ និង ការសរសេរ អំពីអក្សរសិល្ប៍អង់គ្លេស ក្នុងការប្រឡង PSSA ក្នុងជំពូកតែងសេចក្តី។ (មានសម្រាប់សិស្ស ELs ដែលរៀននៅសាលាក្នុងសហរដ្ឋ តិចជាង៣ឆ្នាំ **តែប៉ុណ្ណោះ**)
- ៣) ការប្រឡងជាភាសា អេស្ប៉ាញ៉ុល/អង់គ្លេស និង កូនសៀវភៅសម្រាប់សរសេរចម្លើយ... អនុញ្ញាតឲ្យប្រើក្នុងពេលប្រឡង ឃីស្តូន ផ្នែក ពិជគណិត១ និង ជីវវិទ្យា និង ការប្រឡង PSSAs ផ្នែក គណិតវិទ្យា និង វិទ្យាសាស្ត្រ (មានសម្រាប់សិស្ស ELs ដែលរៀននៅសាលាក្នុងសហរដ្ឋ តិចជាង៣ឆ្នាំ **តែប៉ុណ្ណោះ**)

ការជួយសម្រួល សម្រាប់សិស្ស EL ទាំងបីខាងលើនេះ **គ្មាន**សម្រាប់សិស្សានុសិស្សដែលបានចេញពីកម្មវិធីនោះទេ។

***ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី លក្ខណៈពិសេស និង ការជួយសម្រួល សូមប្រើបណ្តាញតភ្ជាប់ខាងក្រោមនេះ ហើយមើលក្នុងជំពូកនៃ ការជួយសម្រួល៖**

http://www.education.pa.gov/Documents/K-12/Assessment%20and%20Accountability/PSSA/Accommodations/2018%20Accommodations%20Guidelines%20Handbook.pdf

** សម្រាប់តួនាទីរបស់ អ្នកបកប្រែភាសា សូមប្រើបណ្តាញតភ្ជាប់ខាងលើនេះ ហើយបន្ទាប់មកចុចលើពាក្យ 2018 Accommodations Guidelines for ELs (ទំព័រ ៦)